ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

## ព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុន វៃ ខេ លេឌើរ(ខេមបូឌា) ឯ.ក

ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទី២២ វេលាម៉ោង៨:០០នាទីព្រឹក មានបើកកិច្ចប្រជុំនៅក្រុមហ៊ុន វៃ ខេ លេឌើរ (ខេមបូឌា) ឯ.ក ដែលមានទីតាំងនៅភូមិទំពូង ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល ។

ក្រោមអធិបតីភាពលោក LIAO YONG ជានាយកក្រុមហ៊ុននិងលោកផែន បូរ៉ា ប្រធានរដ្ឋបាលបានពិនិត្យអំពីក្រុមហ៊ុនបានជួបវិបត្តិហិរញ្ញវត្ថុ ដោយសារតែក្រុមហ៊ុនយើងខ្ញុំគ្មានការបញ្ជាទិញ ដែលបណ្ដាលមកពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរCovid-19 ។ ដូច្នេះហើយទើបក្រុមហ៊ុនឈានទៅដល់ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២៥៣នាក់ ស្រី១៧៣ នាក់ ប្រុស៨០ នាក់ ។

### សមាសភាពចូលរួម

**-តំណាងនិយោជក**

- លោក LIAO YONG នាយកក្រុមហ៊ុន
- លោក ផែន បូរ៉ា ប្រធានរដ្ឋបាល

**- តំណាងកម្មករនិយោជិត**

- លោក ឡាំ ប៊ុនធឿន ប្រធានសហជីព ស្មារតីកម្មករខ្មែរ នៃក្រុមហ៊ុន វៃ ខេ លេឌើរ (ខេមបូឌា)
- លោក សោម ម៉ានី អនុប្រធានសហជីព ស្មារតីកម្មករខ្មែរ នៃក្រុមហ៊ុន វៃ ខេ លេឌើរ (ខេមបូឌា)
- លោក យុត សុភាព ជាលេខាធិការ សហជីព ស្មារតីកម្មករខ្មែរ នៃក្រុមហ៊ុន វៃ ខេ លេឌើរ (ខេមបូឌា)

លោក ឡាំ ប៊ុនធឿន ប្រធានសហជីព ស្មារតីកម្មករខ្មែរ នៃក្រុមហ៊ុន វៃ ខេ លេឌើរ (ខេមបូឌា) បានមានប្រសាសន៍ថា ក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន ព្រោះគ្មានអ្នកបញ្ជាទិញ ដោយសារជំងឺ COVID-19 ដូច្នេះខ្ញុំមិនជំទាស់នឹងការព្យួរកិច្ចសន្យាការងារនេះទេ ។

លោក សោម ម៉ានី អនុប្រធាននៃសហជីព ស្មារតីកម្មករខ្មែរ ប្រចាំនៅក្រុមហ៊ុន ក៏បានឯកភាពទាំងស្រុងចំពោះការព្យួរកិច្ចសន្យាការងារនេះ ។

នៅក្នុងកិច្ចប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពនាពេលបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្ញុំគ្មានការបញ្ជាទិញ ដែលបណ្ដាលមកពីជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ Covid-19 ។ ហេតុដូច្នេះហើយ ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់រយៈពេល ២ខែ គឺចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២០ ។

**- លទ្ធផលពិភាក្សា**

លោក LIAO YONG នាយកក្រុមហ៊ុន និងតំណាងកម្មករ ហើយប្រធានសហជីពមូលដ្ឋាន បានឯកភាពគ្នាលើការព្យួរកិច្ចសន្យាការងារនេះ ព្រោះក្រុមហ៊ុនពិតជាគ្មានការងារធ្វើមែន ។

- នៅក្នុងអំឡុងពេល នៃការព្យួរកិច្ចសន្យាការងាររយៈពេលពីរខែ ចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២០ ក្រុមហ៊ុនផ្តល់ជូនកម្មករនិយោជិតក្នុងម្នាក់ៗ ៣០ ដុល្លារក្នុងមួយខែ ដោយបើកជូននៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ និង ផ្តល់ជូននៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ សម្រាប់ការព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០ ។
- នៅពេលក្រុមហ៊ុនមានភ្ញៀវបញ្ជាទិញវិញមុនពេលកំណត់ នៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនត្រូវជូនដំណឹងមកមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល មុនរយៈពេល២ថ្ងៃ ។

កិច្ចប្រជុំនេះត្រូវបានបញ្ចប់នៅវេលាម៉ោង១០ និង ៤០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ។

ធ្វើនៅកណ្តាល, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន
WEI KE LEATHER (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

**តំណាងកម្មករនិយោជិត**

ឡាំ ប៊ុនធឿន សោម ម៉ានី

ឃុត សុភាព ឡុញ ស៊ីនួន